**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២០-៣៥០ ប្រ.ក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៩/៦៤២ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ស្តីពី ការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី**
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និង មាត្រា៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី ការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ស្លាកសញ្ញារបស់ប្រព័ន្ធទូទាត់ "បាគង" តទៅនេះហៅថា ប្រព័ន្ធបាគង សម្រាប់ជាសញ្ញាសម្គាល់ដើម្បីប្រើប្រាស់នៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ និងក្នុងការធ្វើប្រតិបត្តិការប្រព័ន្ធបាគង ហើយអនុញ្ញាតឱ្យគ្រឹះស្ថានជាសមាជិកប្រព័ន្ធប្រើសម្រាប់អនុវត្តការងារពាក់ព័ន្ធ ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅរក្សាសង្គតិភាពក្នុងការប្រើប្រាស់ស្លាកសញ្ញារបស់ប្រព័ន្ធបាគងជាសាធារណៈ ធានាពីសិទ្ធិ និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធ និងការពារផលប្រយោជន៍របស់គ្រឹះស្ថាន និងអង្គភាពជាសមាជិកប្រព័ន្ធបាគង។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថាន និងអង្គភាពដែលជាសមាជិកនៃប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤.-**

គ្រឹះស្ថាន និងអង្គភាពដែលជាសមាជិកនៃប្រព័ន្ធបាគង ត្រូវរៀបចំបោះពុម្ព និងប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគងឱ្យបានត្រឹមត្រូវតាមលក្ខណៈសម្គាល់ស្លាកសញ្ញាប្រព័ន្ធបាគង។

**ប្រការ ៥.-**

រាល់ការក្លែងបន្លំ ការប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគងមិនបានត្រឹមត្រូវ ឬ គ្មានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា នឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

**ទេសាភិបាល**

ជា ចាន់តូ

**កន្លែងទទួល៖**

- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**

នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ឧបសម្ព័ន្ធនៃប្រកាសលេខ ធ១៤-០២០-៣៥០ ប្រក ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០២០

# ស្លាកសញ្ញាប្រព័ន្ធបាគង

ធនាគារជាតិនៃកម្ពុជាសូមណែនាំ អំពីការរៀបចំទ្រង់ទ្រាយ សណ្ឋាន និងពណ៌របស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធបាគង ដូចខាងក្រោម៖

## ១. លក្ខណៈសម្គាល់ស្លាកសញ្ញា

ស្លាកសញ្ញាប្រព័ន្ធបាគង ដែលមានរូបដូចប្លង់ប្រាសាទបាគងមើលពីលើ ឬស្លាកសញ្ញាប្រព័ន្ធបាគងមានផ្តុំពាក្យជាខេមរៈភាសា “បាគង” ជាមួយនិងអក្សរឡាតាំង “BAKONG”។

ស្លាកសញ្ញាប្រព័ន្ធ បាគង មាន ២ ទម្រង់ដូចខាងក្រោម៖

- **ស្លាកសញ្ញាទម្រង់ទី១ ៖** ស្លាកសញ្ញាពណ៌ក្រហម និងមានផ្ទៃខាងក្រោយថ្លា (Transparent)។

ឬ

- **ស្លាកសញ្ញាទម្រង់ទី២ ៖** ស្លាកសញ្ញាពណ៌ស និងមានផ្ទៃខាងក្រោយពណ៌ក្រហម។

ឬ

## ២. ទម្រង់នៃស្លាកសញ្ញា

ស្លាកសញ្ញាប្រព័ន្ធបាគង នឹងត្រូវពង្រីក ឬ បង្រួមទំហំតាមសមាមាត្រទម្រង់របស់ស្លាកសញ្ញាដែលបានកំណត់ប្រវែងទទឹងស្មើនឹង X និងប្រវែងបណ្តោយស្មើនឹង X ឬ

ស្លាកសញ្ញាប្រព័ន្ធបាគងមានផ្តុំពាក្យជាខេមរៈភាសា “បាគង” ជាមួយនិងអក្សរឡាតាំង “BAKONG” នឹងត្រូវពង្រីក ឬ បង្រួមទំហំតាមសមាមាត្រទម្រង់របស់ស្លាកសញ្ញាដែលបានកំណត់ប្រវែងទទឹងស្មើនឹង X និងប្រវែងបណ្តោយស្មើនឹង $\frac{៧}{៣}$X។

## ៣. ពណ៌នៃស្លាកសញ្ញា

ពណ៌នៃស្លាកសញ្ញានេះគឺពណ៌ក្រហម និងពណ៌ស ដែលមានពណ៌គោលដូចខាងក្រោម៖

- **ពណ៌ក្រហម** **R: 227** **G: 43** **B:45**
- **ពណ៌ស** **R: 255** **G: 255** **B: 255**

## ៤. ការប្រើប្រាស់ស្លាកសញ្ញា

គ្រឹះស្ថាននិងអង្គភាពជាសមាជិកត្រូវដាក់បង្ហាញស្លាកសញ្ញាប្រព័ន្ធបាគង ដូចបានកំណត់ខាងលើនៅតាមទីតាំងដែលងាយកត់សម្គាល់។